# មេរៀនទី ១៨៖ ព្រះយេស៊ូវបានបង្ហាញខ្លួននៅមុខម៉ារា

[យ៉ូហាន ២០៖១-១៨](#)

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/SnRUuCkGGdY

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/1hRPD_GfloM

**គោលបំណង៖** ព្រះយេស៊ូវមានអំណាចលើសេចក្ដីស្លាប់ ហើយទ្រង់មានព្រះជន្មរស់សព្វថ្ងៃ

**ខគម្ពីរចងចាំ៖ យ៉ូហាន ១១៖២៥** *ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ”។*

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

២. ព្រះអម្ចាស់ទ្រង់ស្ថិតស្ថេរ https://youtu.be/suW4J1Wbxa4

៣. មានទន្លេជីវិត https://youtu.be/AP6fwLxUqK0

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** **« យប់ និងថ្ងៃ»**

សម្ភារៈដែលត្រូវការ៖ ក្រដាសរឹង ឬ ចានជ័រ (ដែលអាចបោះឡើងលើបាន)សូមសរសេរពាក្យថា “ពេលថ្ងៃ” នៅម្ខាង ហើយម្ខាងទៀត សរសេរពាក្យថា “ពេលយប់”




១. ចែកកុមារជា២ក្រុមគឺ ក្រុមថ្ងៃ និងក្រុមយប់ នៅពេលចែកក្រុមរួចហើយ យើងឲ្យក្រុមទាំងពីរឈរជាជួរបែរមុខរកគ្នា

២.គ្រូត្រូវធ្វើជាអាជ្ញាកណ្ដាលរវាងក្រុមទាំង២

៣.គ្រូត្រូវកំណត់ខ្សែទីផងដែរហើយក្រុមដែលត្រូវគេដេញចាប់អាចរត់ហួសខ្សែទីនោះបាន ប៉ុន្តែក្រុមដែរ ត្រូវដេញចាប់គេមិនត្រូវរត់ហួសខ្សែទីនោះឡើយ។

៤. គ្រូបោះចានឬក្រដាសឡើងទៅលើបើចានឬក្រដាសធ្លាក់ប៉ះចំពាក្យ “ពេលថ្ងៃ” ក្រុមថ្ងៃដេញចាប់ក្រុម “ពេលយប់” តែបើក្រដាសឬចានធ្លាក់ប៉ះចំពាក្យ “ពេលយប់” ក្រុមយប់ត្រូវដេញចាប់ក្រុម “ពេលថ្ងៃម្ដង” វិញម្ដង។

បន្ទាប់ពីលេងល្បែងនេះរួចហើយ គ្រូពន្យល់សិស្សថា “ពេលយប់” គឺតំណាងឲ្យសេចក្ដីស្លាប់ ហើយ “ពេលថ្ងៃ” តំណាងឲ្យការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ។

**៤. ការណែនាំមេរៀន**

តើប្អូនធ្លាប់ចូលរួមពិធីបុណ្យសពដែរឬទេ? តើអ្នកចូលរួមមានអារម្មណ៍យ៉ាងណា នៅពេលទៅចូលរួមបុណ្យសព? តើប្អូនធ្លាប់ឃើញមានអ្នកស្លាប់ហើយអាចរស់ឡើងវិញបានដែរឬទេ? យើងទាំងអស់គ្នាដឹងហើយថាគ្មាននរណាម្នាក់មានថាមពលអាចរស់ឡើងវិញបន្ទាប់ពីពួកគេស្លាប់នោះទេ។ តែមានមនុស្សម្នាក់ដែលស្លាប់ហើយ អាចរស់ឡើងវិញបាន! យើងនឹងស្វែងយល់ពីបុគ្គលដ៏ពិសេសម្នាក់នោះ ដែលបានសន្យាថា នឹងផ្ដល់នូវថាមពលដូចគ្នាមកឲ្យយើងរាល់គ្នាតាមរយៈគាត់!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

កាលពីសប្ដាហ៍មុន យើងបានរៀនពីព្រះយេស៊ូវបានសុគតលើឈើឆ្កាងជំនួសអំពើបាបរបស់យើង ដើម្បីឲ្យយើងអាចក្លាយជាចំណែកនៃគ្រួសាររបស់ព្រះបាន។ ក្រោយពីព្រះយេស៊ូវសុគត ព្រះអង្គត្រូវគេបញ្ចុះទៅក្នុងផ្នូរដែលផ្នូរគឺដូចជារូងភ្នំអ៊ីចឹង។ ថ្មដ៏ធំមួយត្រូវបានគេយកមកដាក់នៅមាត់ច្រកចូល។ ក្រោយពីគេបញ្ចុះសពព្រះយេស៊ូវហើយ មិត្តរបស់ទ្រង់ទាំងអស់កើតទុក្ខយ៉ាងខ្លាំង។ ពួកគេគិតថា ពួកគេនឹងមិនអាចឃើញព្រះយេស៊ូវទៀតទេ។ ម៉ារា ម៉ាក់ដាឡា បានទៅឯផ្នូរដែលគេបានបញ្ចុះព្រះយេស៊ូវ។ នាងមានការភ្ញាក់ផ្អើលពេលនាងទៅដល់ទីនោះ ព្រោះដុំថ្មដ៏ធំនោះត្រូវបានរមៀលចេញពីផ្នូរ!

នាងបានរត់ទៅប្រាប់ពេត្រុស និងយ៉ូហាន ដែលជាមិត្តជិតស្និតរបស់ព្រះយេស៊ូវ។ ពេត្រុស និងយ៉ូហានរត់ត្រឡប់ទៅឯផ្នូរវិញ។ ពួកគេបានឃើញតែក្រណាត់ដែលគេរុំសពព្រះយេស៊ូវក្នុងរូងភ្នំ។ ប៉ុន្តែព្រះយេស៊ូវមិនបាននៅទីនោះទេ។ មួយសន្ទុះក្រោយមកពេត្រុស និង យ៉ូហាន បានត្រឡប់ទៅផ្ទះវិញ។

ប៉ុន្តែម៉ារាបាននៅខាងក្រៅផ្នូរ ហើយអង្គុយយំ នាងសោកសៅជាខ្លាំង។ បន្ទាប់មក ម៉ារា មើលទៅក្នុងផ្នូរម្ដងទៀត។ លើកនេះនាងបានឃើញទេវតាពីររូបនៅកន្លែងដែលគេទុកសពព្រះយេស៊ូវ! ទេវតាសួរម៉ារាថាហេតុអ្វីបានជានាងយំ? ពេលនោះ ព្រះយេស៊ូវយាងមកពីក្រោយនាង ហើយហៅឈ្មោះរបស់នាង។ ម៉ារាបានដឹងថាជាព្រះយេស៊ូវ នៅពេលដែលទ្រង់ ហៅឈ្មោះរបស់នាង! ម៉ារាសប្បាយចិត្តណាស់ ពីព្រោះព្រះយេស៊ូវ បានរស់ពីសុគតឡើងវិញ! នាងបានទៅប្រាប់មិត្តភក្តិរបស់នាងអំពីព្រះយេស៊ូវ។

ដោយសារព្រះយេស៊ូវមិនបានសុគតរហូតទេ ប៉ុន្តែទ្រង់បានរស់ឡើងវិញ ហើយយើងដឹងថាទ្រង់គឺជាព្រះ! យើងដឹងថា ព្រះយេស៊ូវមានអំណាចលើសេចក្តីស្លាប់! យើងមិនត្រូវភ័យខ្លាចអ្វីឡើយ ព្រោះអំណាចរបស់ព្រះយេស៊ូវ អាចមើលថែយើង និងជួយយើង ទោះបីជាអំណាច នៃសេចក្តីស្លាប់ក៏ដោយ! ពេលយើងស្លាប់យើងនឹង មានជីវិតរស់ឡើងវិញ ហើយរស់នៅជាមួយនឹងព្រះអស់កល្បជានិច្ច!

## ៦. សំនួរពិភាក្សា

១. តើផ្នូរសំរាប់ដាក់សពនៅសម័យព្រះយេស៊ូវមានរូបរាងដូចម្តេច? *(មានរាងដូចជារូងភ្នំដែលមានថ្មធំនៅមុខច្រកចូល)*

២. តើម៉ារា ម៉ាក់ដាឡា និងពួកសិស្សរកឃើញអ្វីនៅក្នុងផ្នូរ? *(ក្រណាត់ដែលរុំព្រះសពព្រះយេស៊ូវគឺនៅទីនោះ ប៉ុន្តែព្រះយេស៊ូវមិនបាននៅទីនោះទេ)*

៣. តើមានអ្វីកើតឡើងចំពោះព្រះយេស៊ូវ? *(ទ្រង់មានព្រះជន្មរស់ឡើងវិញ!)*

៤. ដោយសារព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ តើបានធ្វើឲ្យអ្នកមានសេចក្តីសង្ឃឹមអ្វីខ្លះ? *(យើងមានសង្ឃឹមថា សេចក្តីស្លាប់មិនមែនជាទីបញ្ចប់សម្រាប់យើងនោះទេ។ យើងនឹងមានជីវិតរស់ឡើងវិញ ហើយរស់នៅជាមួយនឹងព្រះអស់កល្បជានិច្ច)*

## ៧. ល្បែងកំសាន្ត « ផ្ទុះបំបែកសារ! »

សម្ភារៈដែលត្រូវការ៖ ក្រដាសដែលមានសរសេរសារ (សូមមើលខាងក្រោមដើម្បីបោះពុម្ព) ប៉េងប៉ោង

| | |
|---|---|
| ទ្រង់មានព្រះជន្មរស់ឡើងវិញពិតប្រាកដមែន! | ព្រះយេស៊ូវនៅមានព្រះជន្មរស់! |
| ព្រះយេស៊ូវសុគតសំរាប់អំពើបាបយើង! | ព្រះគ្រីស្ទជាព្រះដែលមានព្រះជន្មរស់ឡើងវិញដល់សព្វថ្ងៃនេះ! |
| សរសើរដំកើងព្រះ! ផ្នូរទទេ! | ខ្ញុំអាចទៅស្ថានសួគ៌បាន ដោយសារព្រះយេស៊ូវមានព្រះជន្មរស់! |
| ទ្រង់មានព្រះជន្មរស់ឡើងវិញដូចទ្រង់មានបន្ទូល! | ជឿលើអំណាចនៃការរស់ឡើងវិញ! |
| ចេញពីផ្នូរ ទ្រង់បានរស់ឡើងវិញ! | ព្រះគ្រីស្ទបានរស់ឡើងវិញ! ស្រែកឡើង "ហូសាណា!" |



១. មុនពេលកុមារចូលមកក្នុងថ្នាក់រៀន សូមរៀបចំដាក់ក្រដាសសារ ទៅក្នុងប៉េងប៉ោង ហើយផ្លុំឲ្យប៉ោង។

២. ពន្យល់កុមារថាសូមចាត់ទុកប៉េងប៉ោងដូចជាផ្នូរដែលព្រះយេស៊ូវ ត្រូវបានគេយកទៅបញ្ចុះ។ នៅពេលដែលពួកសិស្សមក ពួកគេមិនឃើញព្រះសពរបស់ព្រះយេស៊ូវនៅក្នុងផ្នូរទេ។ ពួកគេឃើញតែក្រណាត់ដែលរុំ ព្រះ-សព របស់ទ្រង់តែប៉ុណ្ណោះ។ នេះដូចជាការរំឭកផងដែរថាព្រះយេស៊ូវ

គង់នៅទីនោះ។ នៅខាងក្នុងប៉េងប៉ោងនីមួយៗ អ្នកឃើញមានសារដែលរំឭកអ្នកអំពីព្រះយេស៊ូវ។



៣. ឲ្យប៉េងប៉ោង ទៅកុមារម្នាក់មួយៗ ហើយឱ្យពួកគេបំបែកប៉េងប៉ោងនោះ ដើម្បីស្វែង រកសាររំលឹកពួកគេអំពីព្រះយេស៊ូវ។

៤. ពេលគេរកឃើញសារនេះហើយគេត្រូវស្រែកប្រាប់អ្នករាល់គ្នា!

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន ១១:២៥** *"ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិតអ្នកណាដែលជឿលខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ"*។

## ៩. ហត្ថកម្ម

សូមបោះពុម្ពរូបភាព ដើម្បីឲ្យកុមារផាត់ពណ៌ ហើយឱ្យពួកគេសរសេរខគម្ពីរចងចាំនៅលើក្រដាសនោះ។

## ១០. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ: (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
បន្ទាប់ពីបានឃើញការអស្ចារ្យដែលមិនគួរឱ្យជឿដែលឃើញសពបុរសម្នាក់(ឡាសារ) បានរស់ឡើងវិញ ហើយបានឮការព្យាករណ៍របស់ព្រះយេស៊ូវអំពីការសុគតរបស់ទ្រង់នោះ ពួកសិស្សនៅតែមិនរំពឹងថា នឹងមានទីបញ្ចប់ដ៏រីករាយចំពោះការឆ្កាងព្រះយេស៊ូវដែរ។ ការរស់ឡើងវិញរបស់ព្រះយេស៊ូវ បានផ្លាស់ប្តូរអ្វីៗទាំងអស់ ហើយបានផ្តល់ឱ្យពួកសិស្សនូវភាពក្លាហានដែលពួកគេត្រូវការ ដើម្បីប្រឈមមុខ នឹងការស្លាប់របស់ពួកគេដោយគ្មានការភ័យខ្លាច។ តើការរស់ឡើងវិញរបស់ព្រះគ្រីស្ទបានផ្លាស់ប្តូរ របៀបរស់នៅរបស់អ្នកយ៉ាងដូចម្តេច? ថ្ងៃនេះ សូមចែកចាយពីអំណាច និងសេចក្តីអំណរដែលយើងអាចរកឃើញនៅក្នុងការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវជាមួយកុមារ។

# ល្បែងកំសាន្ត៖ បំបែកសារ!

| | |
|---|---|
| ទ្រង់មានព្រះជន្មរស់ឡើងវិញ ពិតប្រាកដមែន! | ព្រះយេស៊ូវនៅមានព្រះជន្មរស់! |
| ព្រះយេស៊ូវសុគត សំរាប់អំពើបាបយើង! | ព្រះគ្រីស្ទជាព្រះដែលមានព្រះជន្ម រស់ឡើងវិញដល់សព្វថ្ងៃនេះ! |
| សរសើរដំកើងព្រះ! ផ្នូរទទេ! | ខ្ញុំអាចទៅស្ថានសួគ៌បាន ដោយ សារព្រះយេស៊ូវមានព្រះជន្មរស់! |
| ទ្រង់មានព្រះជន្មរស់ឡើងវិញ ដូចទ្រង់មានបន្ទូល! | ជឿលើអំណាចនៃការ រស់ឡើងវិញ! |
| ចេញពីផ្នូរ ទ្រង់បានរស់ឡើងវិញ! | ព្រះគ្រីស្ទបានរស់ឡើងវិញ! ស្រែកឡើង “ហូសាណា!” |




ខគម្ពីរចងចាំ ______________________________

______________________________________________

______________________________________________